# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ១៨៩ ព.ណ.កា.ព.

ថ្ងៃសុក្រ ១២រោច ខែស្រាពណ៍ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ ២០១៨

## សេចក្ដីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជូនដំណឹងដល់សាធារណជនឲ្យបានជ្រាបថា ក្រសួងនឹងរៀបចំ **"ពិព័រណ៍ផលិតផលខ្មែរ និងផលិតផលនាំចេញ-នាំចូលកម្ពុជា លើកទី១៣ កម្រិតអន្តរជាតិ"** ពីថ្ងៃទី០៨-១១ ខែធ្នូ ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលពិព័រណ៍ និងសន្និបាតកោះពេជ្រ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ព្រឹត្តិការណ៍ពិព័រណ៍នេះ នឹងត្រូវបានរៀបចំអមជាមួយផងដែរ នូវព្រឹត្តិការណ៍សំខាន់ៗជាច្រើន ដូចជា វេទិកាស្ដីពីវិនិយោគ និងធុរកិច្ច សិក្ខាសាលាស្ដីពីការជំរុញសកម្មភាពពាណិជ្ជកម្ម ជំនួបពាណិជ្ជកម្ម និងកម្មវិធីចុះហត្ថលេខាលើកិច្ចសន្យាពាណិជ្ជកម្ម និងវិនិយោគជាដើម។ លើសពីនេះទៀត ក្រសួងពាណិជ្ជកម្មក៏នឹងដាក់តាំងបង្ហាញផលិតផលស្រូវ-អង្ករ និងរៀបចំកម្មវិធីជំនួបពាណិជ្ជកម្មសម្រាប់អ្នកនាំចេញអង្ករកម្ពុជា ផងដែរ។

ការរៀបចំព្រឹត្តិការណ៍ទាំងនេះ គឺក្នុងបំណងជំរុញសកម្មភាពពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា ជាពិសេស ការជំរុញការនាំចេញ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ព្រឹត្តិការណ៍ពាណិជ្ជកម្មនេះ ក៏នឹងផ្ដល់នូវកាលានុវត្តភាព ដើម្បីជំរុញឲ្យបរិយាកាសពាណិជ្ជកម្មក្នុងស្រុកមានសន្ទុះឡើង និងដើម្បីបង្កើតការ តភ្ជាប់ពាណិជ្ជកម្មក្នុងស្រុករវាងរាជធានី-ខេត្ត ទូទាំងប្រទេសកម្ពុជា និងរវាងកម្ពុជា និងពាណិជ្ជករបរទេស។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ពាណិជ្ជករ អាជីវករ ដែលមានបំណងចូលរួមក្នុងព្រឹត្តិការណ៍ **ពិព័រណ៍ផលិតផលខ្មែរ និងផលិតផលនាំចេញ-នាំចូលកម្ពុជា លើកទី១៣ ឆ្នាំ២០១៨** ឬមានគម្រោងស្វែងរកដៃគូវិនិយោគ ឬត្រូវចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយដៃគូរបស់ខ្លួន សូមអញ្ជើញមកបំពេញបែបបទ និងផ្ញើគម្រោងរបស់ខ្លួន មកអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ឲ្យបានមុនថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ជាកំហិត។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ដែលមានទីតាំង ស្ថិតនៅជាន់ទីពីរ នៃអាគារទីស្ដីការក្រសួងពាណិជ្ជកម្ម, អាសយដ្ឋាន៖ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទទាក់ទង៖ ០៧៧ ៣៣៩ ៤៣៩ ឬ ០១៥ ៥៥៣ ៣៥៥ ឬ<br>០៧៧ ៣៣២ ២៣៣ ឬ ០៩៨ ៨៤២ ១១៩

អាសយដ្ឋានអ៊ីមែល៖ neary86@gmail.com ឬ rithyco@yahoo.com ឬ<br>vuthakep@yahoo.com ឬ sok.danith@moc.gov.kh។

សូមអរគុណ!

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce
N°3189MOC.D./..EA

# KINGDOM OF CAMBODIA
## Nation - Religion - King

Phnom Penh, 03 September, 2018

## ANNOUNCEMENT

The Ministry of Commerce has the honor to inform the public that the Ministry will organize **"The 13th Cambodian and Import-Export Products Exhibition, International level"** which will be held from 08th to 11th December 2018 at the Koh Pich Exhibition & Convention Center, Phnom Penh, Kingdom of Cambodia.

The event will be accompanied by relevant events such as forum on Investment and Business, Seminar on Promotion of Business Activities, Business Matching and Signing Ceremony of Trade and Investment Contracts. In addition, the Ministry will display rice products and organize a business matching for Cambodian rice exporters as well.

The organization of these events is aimed to promote trade and investment activities, especially to increase export activities for contribution to the development of Cambodian economy. Moreover, these events will create more opportunities and give strong impetus to local business activities and establish trade linkages between municipality and provinces throughout Cambodia as well as between Cambodian and foreign businesses.

Businesspeople who wish to participate in **The 13th Cambodian and Import-Export Products Exhibition 2018** or wish to find their investment partners or to sign agreements or MOU with their counterparts are requested to apply and submit their proposal to General Directorate of Trade Promotion of Ministry of Commerce **no later than 11th November 2018**.

For further details, please contact General Directorate of Trade Promotion, Ministry of Commerce at Lot 19-61, Russian Federation Blvd, Teuk Thla Village, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Cambodia.

Contact numbers: 077 339 439 / 015 553 355
077 332 233 / 098 842 119
E-mail Address: neary86@yahoo.com / rityco@yahoo.com
vuthakep@yahoo.com / sok.darith@moc.gov.kh

Thank you!